ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៣២២ ប្រក.កសក

# ប្រកាស
## ស្តីពី
## ការបង្កើតនិងការគ្រប់គ្រងតំបន់ព្រៃសហគមន៍ក្នុងខេត្តកោះកុង

**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឲ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលំអដីកសិកម្មឲ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៧៩ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០៣ ស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ
- បានឃើញប្រកាសលេខ ២១៩ ប្រក.កសក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ
- តាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកប្រធានរដ្ឋបាលព្រៃឈើ



អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
No. 200 Preah Norodom Blvd, Sangkat Tonle Basak, Khan Chamkarmon Phnom Penh, Cambodia
Phone: (023) 726 428, 726 129 Fax: (855) 23 217 320

## សម្រេច

**ប្រការ ១.-**

*បង្កើតតំបន់ព្រៃសហគមន៍ក្នុងខេត្តកោះកុង សម្រាប់ធ្វើការគ្រប់គ្រងប្រកបដោយនិរន្តរភាពតាមលក្ខណៈសហគមន៍ព្រៃឈើដែលមានទីតាំងស្ថិតនៅក្នុងសង្កាត់រដ្ឋបាលព្រៃឈើបុទុមសាគរ ផ្នែករដ្ឋបាលព្រៃឈើអណ្តូងទឹកនៃខណ្ឌរដ្ឋបាលព្រៃឈើកោះកុង ។*

**ប្រការ ២.-**

*ការបង្កើតតំបន់ព្រៃសហគមន៍នេះមានគោលបំណង ៖*

- *គ្រប់គ្រង ប្រើប្រាស់ ការពារ ថែរក្សា អភិរក្សជីវចម្រុះនិងអភិវឌ្ឍព្រៃសហគមន៍ឲ្យមាននិរន្តរភាព*
- *ប្រើប្រាស់ផល អនុផលព្រៃឈើជាលក្ខណៈប្រពៃណីសម្រាប់ការរស់នៅ ទំនៀមទម្លាប់និងជំនឿសាសនា*
- *ទាញយកផល អនុផលព្រៃឈើ ស្របតាមលទ្ធភាពធនធាននិងសក្តានុពលព្រៃសហគមន៍*
- *គាំទ្រដល់គោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ ។*

**ប្រការ ៣.-**

*តំបន់ព្រៃសហគមន៍ក្នុងខេត្តកោះកុងនៃប្រកាសនេះមាន មួយ(១)សហគមន៍ព្រៃឈើដែលមានផ្ទៃដីមួយកន្លែងសរុបចំនួន ៣ ០១៣ (បីពាន់ដប់បី)ហិកតា ដូចមានក្នុងផែនទីភ្ជាប់ជាឧបសម្ព័ន្ធ១នៃប្រកាសនេះនិងជាប្រព័ន្ធខ្សែព្រំប្រទល់ដោយចំណុចគោលនិងនិយាមកាដូចបានកំណត់ក្នុងឧបសម្ព័ន្ធ២នៃប្រកាសនេះ ។*

**ប្រការ ៤.-**

*ដំណើរការរៀបចំនិងការប្រព្រឹត្តទៅនៃសហគមន៍ព្រៃឈើក្នុងតំបន់ព្រៃសហគមន៍នៃប្រកាសនេះ ត្រូវអនុវត្តតាមនីតិវិធីដូចបានកំណត់នៅក្នុងច្បាប់ស្តីពីព្រៃឈើ អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើនិងប្រកាសស្តីពីគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ ។*

**ប្រការ ៥.-**

*ប្រកាស ឬសេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។*

**ប្រការ ៦..**

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធានរដ្ឋបាលព្រៃឈើ ប្រធាននាយកដ្ឋានទីតាំងកសិកម្ម ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ ប្រធានអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ដែលពាក់ព័ន្ធ និងប្រធានមន្ទីរកសិកម្មខេត្តកោះកុង ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១២

**រដ្ឋមន្ត្រី**

ចន់ សារុន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងការពារជាតិ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងបរិស្ថាន
- សាលាខេត្តកោះកុង
- ដូចប្រការ ៦

ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ ១ : ប្រកាសលេខ ៣២២....ប្រក.កសក ចុះថ្ងៃទី ២១... ខែ ឧសភា.... ឆ្នាំ ..២០១២




1:50,000
Coordinate Systems
Zone: 48P
Projection: UTM
Map Datum: Indian 1960
N
E
S
W
Km
0 0.5 1 2

| ចំណុចនិយាមការព្រៃសហគមន៍សុវណ្ណាបៃតង | | | | | |
|---|---|---|---|---|---|
| ID | X | Y | ID | X | Y |
| 1 | 335001 | 1241349 | 18 | 337886 | 1240253 |
| 2 | 335037 | 1241512 | 19 | 338037 | 1240015 |
| 3 | 334999 | 1241649 | 20 | 338829 | 1239768 |
| 4 | 338439 | 1243930 | 21 | 338703 | 1239391 |
| 5 | 342902 | 1243768 | 22 | 338599 | 1239298 |
| 6 | 344791 | 1242011 | 23 | 338623 | 1238741 |
| 7 | 344791 | 1240031 | 24 | 338315 | 1238575 |
| 8 | 338792 | 1240015 | 25 | 337821 | 1239096 |
| 9 | 338971 | 1240249 | 26 | 336600 | 1239253 |
| 10 | 338971 | 1240432 | 27 | 336811 | 1240010 |
| 11 | 339889 | 1240434 | 28 | 335997 | 1240009 |
| 12 | 339890 | 1240925 | 29 | 336000 | 1240288 |
| 13 | 339859 | 1241057 | 30 | 335276 | 1240376 |
| 14 | 339861 | 1241842 | 31 | 334985 | 1240548 |
| 15 | 339251 | 1241842 | 32 | 334990 | 1240957 |
| 16 | 339251 | 1241338 | 33 | 337429 | 1240960 |
| 17 | 337881 | 1241350 | 34 | 337429 | 1241349 |

ឧបសម្ព័ន្ធ ២៖ ភ្ជាប់ប្រកាសលេខ ៣៧២ ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១២

# ទីតាំងព្រៃសហគមន៍ក្នុងខេត្តកោះកុង

| លរ | ឈ្មោះសហគមន៍ព្រៃឈើ | ផ្ទៃដី (ហិកតា) | ចំណុចនិយាមកា ទីតាំងព្រៃសហគមន៍ | | | | ចំនួនភូមិ | ឈ្មោះ ឃុំ | ឈ្មោះស្រុក | ផ្នែករដ្ឋបាលព្រៃឈើ |
|---|---|---|---|---|---|---|---|---|---|---|
| ១ | សុវណ្ណាបៃតង | ៣០១៣ | 335001-1241349<br>335037-1241512<br>334999-1241649<br>338439-1243930<br>342902-1243768<br>344791-1242011<br>344791-1240031<br>338792-1240015<br>338971-1240249 | 338971-1240432<br>339889-1240434<br>339890-1240925<br>339859-1241057<br>339861-1241842<br>339251-1241842<br>339251-1241338<br>337881-1241350<br>337886-1240253 | 338829-1239768<br>338703-1239391<br>338599-1239298<br>338623-1238741<br>338315-1238575<br>337821-1239096<br>336600-1239253<br>338037-1240015 | 335997-1240009<br>336000-1240288<br>335276-1240376<br>334985-1240548<br>334990-1240957<br>337429-1240960<br>337429-1241349<br>336811-1240010 | ១ | កណ្តោល | បុទុមសាគរ | អណ្តូងទឹក |
| សរុប | | ៣០១៣ | | | | | ០១ | ០១ | ០១ | ០១ |